ទន្លេរស្មី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ អំពីព្រះពុទ្ធព្រះនាមព្រះសិអារ្យមេត្រីដែលបាននិយាយក្នុងព្រះពុទ្ធសាសនា

Website: www.hoksavann.org

ថ្ងៃទី១៩ ធ្នូ ២០០៤

ក្នុងព្រះពុទ្ធសាសនានិយាយថា សុញ្ញកប្បប្រែថាកប្បសូន្យ គឺកប្បដែលគ្មានព្រះពុទ្ធត្រាស់ដឹង, អសុញ្ញកប្ប ប្រែថាកប្បមិនសូន្យ គឺកប្បដែលមានព្រះពុទ្ធត្រាស់ដឹង ។ កប្បដែលមានព្រះពុទ្ធត្រាស់ដឹង មានចំនួនព្រះពុទ្ធត្រាស់ដឹងពុំស្មើគ្នាទេ ចំពោះកប្បបច្ចុប្បន្ននេះហៅថា ភទ្ទកប្ប ប្រែថាកប្បចំរើន មានព្រះពុទ្ធត្រាស់ដឹង៥អង្គ គឺព្រះពុទ្ធព្រះនាម កក្កុសន្ធោ, កោនាគមនោ, កស្សបោ, គោត្តមោ និងព្រះអរិយមេត្តេយ្យ ឬព្រះសិអារ្យមេត្រី ។ កប្បមានព្រះពុទ្ធត្រាស់ដឹងមួយអង្គហៅថា សារកប្ប ត្រាស់២អង្គហៅថា មណ្ឌកប្ប និងត្រាស់៣អង្គហៅថា វរកប្ប, ត្រាស់៤អង្គហៅថា សារមណ្ឌកប្ប និងត្រាស់៥អង្គហៅថា ភទ្ទកប្ប ។ ក្នុងភទ្ទកប្បដែលមានព្រះពុទ្ធត្រាស់ដឹង៥អង្គនោះ ព្រះពុទ្ធ៤ព្រះអង្គបានត្រាស់ដឹងនិងបរិនិព្វានទៅហើយ ព្រះពុទ្ធទី៤ដែលបរិនិព្វានហើយ ប៉ុន្តែនៅធម៌វិន័យទុកឲ្យមនុស្សសត្វប្រតិបត្តិសព្វថ្ងៃនេះ គឺព្រះពុទ្ធព្រះនាមព្រះសមណគោតម ចំណែកព្រះពុទ្ធទី៥ គឺព្រះពុទ្ធព្រះនាមព្រះសិអារ្យមេត្រីពុំទាន់ត្រាស់ដឹងនៅឡើយ ។ ព្រះពុទ្ធសមណគោតម ព្រះអង្គត្រាស់ដឹងក្នុងព្រះជន្ម៣៥ព្រះវស្សា ហើយបរិនិព្វានក្នុងព្រះជន្ម៨០ព្រះវស្សា ក្នុងពេលដែលព្រះអង្គបានសំដែងធម៌ទេសនាប្រោសសត្វអស់រយ:ពេល៤៥ព្រះវស្សារួចហើយ ។ ចម្លើយទៅនឹងសំនួរថា បន្ទាប់ពីព្រះអង្គបរិនិព្វានទៅតើសាសនាព្រះអង្គត្រូវអស់ត្រឹមនេះ ឬនៅមានបន្តទៅទៀត ? ព្រះអង្គបានឆ្លើយទៅកាន់សាវករបស់ព្រះអង្គថា តាមតែព្រះអង្គប្រមើមើលទៅអនាគតសាសនាព្រះអង្គ មនុស្សលោកអាចទទួលប្រតិបត្តិតាមចំនួន ៥,០០០ឆ្នាំទៅមុខទៀត ។ តាមចម្លើយព្រះអង្គនេះបញ្ជាក់ថា ព្រះអង្គបរិនិព្វានទៅ ប៉ុន្តែនៅធម៌វិន័យដែលព្រះអង្គបានសំដែង ហើយទុកសំរាប់មនុស្សសត្វប្រតិបត្តិតាម ។ ឥឡូវនេះ សាសនាព្រះពុទ្ធសមណគោតមកន្លងបានជាងពាក់កណ្តាលបន្តិចប៉ុណ្ណោះ ។ បន្ទាប់ពីគ្រប់៥,០០០ឆ្នាំព្រះពុទ្ធទី៥ គឺព្រះសិអារ្យមេត្រីពុំទាន់ត្រាស់ដឹងនៅលើយទេ គឺរាប់ពាន់ឆ្នាំទៅមុខទៀតទើបព្រះអង្គត្រាស់ដឹង ។

ព្រះសិអារ្យមេត្រី ព្រះអង្គកើតក្នុងត្រកូលព្រាហ្មណ៍ ដែលជាធំក្នុងនគរកេតុមតី មាតារបស់ព្រះអង្គព្រះនាមព្រហ្មវតី បិតាព្រះនាមសុព្រហ្ម ។ សម័យនោះ មនុស្សបរិបូណ៌ដោយសេចក្តីសុខ ។ ព្រះសិអារ្យមេត្រី ព្រះអង្គមានព្រះជន្មវែង ការសំដែងធម៌ទេសនាក៏បានយូរអង្វែង ។ កាលព្រះពុទ្ធព្រះនាមព្រះសិអារ្យមេត្រីបរិនិព្វានកន្លងយូរបន្តិចទៅទៀតភទ្ទកប្បផែនដីយើងនេះដល់កំណត់អាយុហើយ ក៏ត្រូវភ្លើងឆេះរំលាយឲ្យវិនាសក្នុងពេលនោះឯង ។ សម័យព្រះពុទ្ធព្រះសិអារ្យមេត្រីមនុស្សមានសេចក្តីសុខច្រើន ដូច្នេះហើយបានជាពុទ្ធសាសនិកជនខ្មែរធ្វើបុណ្យប្រាថ្នាជួបព្រះព្រះសិអារ្យមេត្រី ដើម្បីបានសំរេចមគ្គផលនិព្វាន ។ តាមពិតពុំគួររង់ចាំព្រះសិអារ្យមេត្រីទេ គួរប្រតិបត្តិតាមធម៌របស់ព្រះពុទ្ធសមណគោតមឲ្យបានសំរេចមគ្គផល ព្រោះបើរង់ចាំត្រូវកើតចាស់ឈឺស្លាប់យូរអង្វែងណាស់ ។ ព្រះពុទ្ធគ្រប់ព្រះអង្គទាំងអតីតបច្ចុប្បន្ននិងអនាគតមានការត្រាស់ដឹងធម៌ដូចគ្នា ។ ដូច្នេះការជួបព្រះពុទ្ធណាក៏ដូចព្រះពុទ្ធណាដែរ សំខាន់នៅលើការស្តាប់ធម៌បាន ហើយយកមកប្រតិបត្តិតាមព្រះពុទ្ធគ្រាន់តែបង្ហាញផ្លូវប្រតិបត្តិប៉ុណ្ណោះ ។

ចំពោះអ្នកផ្សាយគ្រីស្តសាសនាខ្មែរខ្លះ ដោយសង្កេតឃើញថា ពុទ្ធសាសនិកជនខ្មែរយកចិត្តទុកដាក់ព្រះពុទ្ធព្រះសិអារ្យមេត្រីដែលពុំទាន់បានត្រាស់ ពួកគេក៏បានឆ្លៀតឱកាសឃោសនាដោយបន្លំថា ព្រះយេស៊ូគ្រិស្តនៃសាសនាគ្រិស្តនេះហើយ ជាព្រះសិអារ្យមេត្រីជាព្រះសង្គ្រោះព្រះអង្គយាងមកហើយ ។ វិធីឃោសនាដោយការបញ្ឆោតនេះ ពុទ្ធសាសនិកជនខ្មែរគ្មានការយកចិត្តទុកដាក់ឡើយ ដោយដឹងច្បាស់ថា នេះគ្រាន់តែជាល្បិចរបស់អ្នកផ្សាយគ្រិស្តសាសនា ដោយឃោសនាអែបនឹងព្រះពុទ្ធសាសនា ដើម្បីទាក់ទាញជំនឿទៅលើព្រះយេស៊ូ ។ ដូចបានរៀបរាប់មកហើយ ព្រះពុទ្ធព្រះសិអារ្យមេត្រីពុំទាន់ត្រាស់ដឹងនៅឡើយទេ ព្រោះតាមធម្មតាព្រះពុទ្ធពុំដែលត្រាស់ដឹងពីរព្រះអង្គក្នុងពេលជាមួយគ្នាឡើយ ព្រោះការឃើញសច្ចធម៌ឃើញដូចតែគ្នា ទោះបីព្រះពុទ្ធត្រាស់ដឹងកន្លងមកហើយក្តី បច្ចុប្បន្ននេះក្តី និងត្រាស់ដឹងនៅពេលអនាគតក្តី ។ ដូច្នេះអ្នកផ្សាយគ្រិស្តសាសនាឃោសនាខុសពីការពិត ដោយចាត់ទុកព្រះយេស៊ូជាព្រះសិអារ្យមេត្រី នោះនាំឲ្យខូចតម្លៃខ្លួនឯងទេ ហើយការឃោសនានេះមិនខុសពីសាសនាព្រាហ្មណ៍ ដែលចាត់ទុកព្រះពុទ្ធជាអវតារទី៩នៃព្រះវិស្ណុ នៅក្នុងគោលបំណងដើម្បីទាញយកពុទ្ធសាសនិកជន ដែលមានចំនួនកាន់តែច្រើនឡើង ឲ្យចូលកាន់សាសនាព្រាហ្មណ៍វិញ ព្រោះព្រះពុទ្ធជាតួអង្គបែងភាគពីព្រះវិស្ណុទេ ។ ដោយពិបាកបង្វែគំនិតខ្មែរឲ្យជឿគ្រិស្តសាសនាពេក អ្នកផ្សាយគ្រីស្តសាសនាបានប្រើវិធីមួយទៀត គឺគេលើកយកពាក្យព្រះពុទ្ធខ្លះមកប្រើ ដូចជាពាក្យថាបាបបុណ្យគុណទោសជាដើម ដើម្បីឲ្យពុទ្ធសាសនិកជនខ្មែរច្រឡំថា គ្រិស្តសាសនាមានពាក្យប្រៀបប្រដៅកន្លែងខ្លះដូចពុទ្ធសាសនាដែរ ។ តាមពិតវិញ ពាក្យប្រៀនប្រដៅខុសគ្នាស្រឡះ គឺព្រះពុទ្ធសាសនាសេចក្តីសុខទុក្ខចំរើនវិនាសស្ថិតនៅលើអំពើរបស់ខ្លួន ចំណែកគ្រិស្តសាសនាវិញ សេចក្តីសុខទុក្ខចំរើនវិនាសស្ថិតនៅលើព្រះជាម្ចាស់គឺព្រះយេហូវ៉ា បើលោកសព្វព្រះទ័យលោកនឹងផ្តល់សុខឲ្យ បើលោកមិនសព្វព្រះទ័យទេ លោកនឹងផ្តល់ទុក្ខឲ្យ មានធ្លាក់នរកជាដើម ។